# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**

**និងប្រព័ន្ធយុត្តិធម៌**

**អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍**

## កំណត់ហេតុ

## កិច្ចប្រជុំស្តីពីការពង្រីកគម្រោងបង្កើតតុលាការតំរូវនៅប្រទេសកម្ពុជា

ឆ្នាំពីរពាន់ប្រាំពីរ ខែ ឧសភា ថ្ងៃទី ដប់ប្រាំពីរ វេលាម៉ោងពីរ និងសាមសិបនាទី នៅសាលប្រជុំរបស់ក្រុមប្រឹក្សា កំណែទម្រង់ច្បាប់ និងប្រពន្ឋ័យុត្តិធម៌ មានរៀបចំកិច្ចប្រជុំមួយក្រោមអធិបតីភាពរបស់ ឯកឧត្តម ស៊ុំ ម៉ានិត ប្រធានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ឋ័យុត្តិធម៌ ដើម្បីពិនិត្យ និងពិភាក្សាអំពីការ ” ពង្រីកគម្រោងតុលាការតំរូវនៅប្រទេសកម្ពុជា “ ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់មកជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **ស៊ុំ ម៉ានិត** បានរំលឹកថា កិច្ចប្រជុំលើកមុនបានប្រារព្ធធ្វើនៅខែ សីហា ឆ្នាំ **២០០៦** ហើយឯកឧត្តមសង្ឃឹមថា កិច្ចប្រជុំថ្ងៃនេះនឹងជំរុញដំណើរការឱ្យបានរហ័ស បានផ្តែផ្កាជាក់ស្តែងសម្រាប់ដាក់ជូនក្រុម ប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ឋ័យុត្តិធម៌ និងរដ្ឋាភិបាល ឯកឧត្តមសារភាពថា មិនស្មានថា ការបង្កើតតុលាការតំរូ បន្ថែមនេះ ស៊ីពេលយូរយ៉ាងនេះសោះ ។

ជាបន្ទាប់ ឯកឧត្តម **ស៊ុយ ម៉ុងលាង** នាយកអង្គភាពគ្រប់គ្រងគម្រោង បានជម្រាបជូនអំពីគោលការណ៍នៃ ការពង្រីកគម្រោងបង្កើតតុលាការតំរូ ។ ឯកឧត្តមក៏បានរំលឹកអំពីការប្រជុំកាលពីខែ សីហា ឆ្នាំ **២០០៦** នៅក្រសួង យុត្តិធម៌ដែលបានសម្រេចថា នឹងបន្តគម្រោងតុលាការតំរូនេះ ដោយខាងកំណែទម្រង់ច្បាប់ និងប្រពន្ឋ័យុត្តិធម៌ទទួល ភារកិច្ចតាមដាន និងបន្តដំណើរការនេះ ។ ឯកឧត្តមបានជម្រាបជូនអង្គប្រជុំជាបន្តថា ការយឺតយ៉ាវនៅក្នុងការបន្តគម្រោង នេះ មានការពាក់ព័ន្ឋនឹងបញ្ហាហិរញ្ញវត្ថុ តែពេលនេះបញ្ហានេះត្រូវបាន ដោះស្រាយហើយដោយមានការគាំទ្រហិរញ្ញវត្ថុពី DANIDA &AusAid ។

ឯកឧត្តមបានមានប្រសាសន៍ទៀតថា ការប្រជុំថ្ងៃនេះ គឺដើម្បីមន្ត្រាពិភាក្សា និងផ្តល់ជាមតយោបល់លើគម្រោងបង្កើតតុលាការគំរូនេះជាបន្តទៅមុខទៀត ។

លោក Thomas Trier ចៅក្រមនៃតុលាការជាន់ខ្ពស់មកពីប្រទេសដាណឺម៉ាក បានលើកបង្ហាញអំពីតុលាការ គំរូនៅ Green Land ហើយជាបន្ទាប់លោកបានធ្វើបទឧទ្ទេសនាមជូនអង្គប្រជុំអំពីតារាង Matrix សម្រាប់តុលាការគំរូនៅប្រទេសកម្ពុជាតាមរយៈការបញ្ចាំងស្លាយដូច មានជូនភ្ជាប់ជាមួយ។

ឯកឧត្តម **ស៊ុំ ម៉ានិត** សំណូមពរឱ្យអង្គប្រជុំមានសំណួរលើបទបង្ហាញរបស់លោក Trier ។

លោក Kamiki Atsushi អ្នកតំណាង JICA បានសួរថា ទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី យើងត្រូវ តាក់តែងលិខិតបទដ្ឋានខ្លះដែលពុំទាន់មាន ដើម្បីការអនុវត្តដូច្នេះនឹងមានការលំបាកចំពោះការបង្កើតតុលាការគំរូនេះ ។ សព្វថ្ងៃនេះ JICA និងក្រសួងយុត្តិធម៌កំពុងតែរៀបចំសៀវភៅមគ្គុទ្ទេសស្តីពីការធ្វើយ៉ាងណាដើម្បីអនុវត្តក្រម នីតិវិធី-រដ្ឋប្បវេណី។

លោក Michael Engquist តំណាង DANIDA បានប្តេជ្ញាជាថ្មីម្តងទៀតចំពោះការគាំទ្រទៅលើដំណើរការ ។ ដើម្បីឆ្លើយតបទៅនឹងតំណាង JICA លោកយល់ថា យកល្អគួរធ្វើកិច្ចការទាំងអស់ឱ្យស្របគ្នាតែម្តង ។ បន្ទាប់មកបាន ចោទសួរថា ការជ្រើសរើសតុលាការគំរូនោះ តើយើងគួររៀបចំតុលាការទាំងមូល ឬមួយគ្រាន់យកតែបញ្ហាទាក់ទងនឹងវិវាទព្រហ្មទណ្ឌ ឬពាណិជ្ជកម្ម ឬក៏ស៊ីវិល ជាដើម ?

លោក Thomas Trier បានពន្យល់ថា យើងនឹងធ្វើការជាមួយតុលាការទាំងមូល ។ ថ្ងៃនេះយើងបានបង្ហាញ ជូននូវស្តង់ដារ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការងារពាក់ព័ន្ធនឹងព្រហ្មទណ្ឌ ប៉ុន្តែក្រុមការងារបច្ចេកទេស នឹងធ្វើកិច្ចការ ពាក់ព័ន្ធនឹងបញ្ហាផ្សេងទៀត ដែលជាតួនាទីរបស់តុលាការ ។

ឯកឧត្តម **ចាន់ រ៉ូរ៉ាកេន** អគ្គព្រះរាជអាជ្ញា បានជម្រាបជូនអង្គប្រជុំថា គម្រោងនេះមានសារសំខាន់ណាស់ ក៏ ប៉ុន្តែដើម្បីធ្វើតាមដំណើរការបង្ហាញដោយលោក Trier ចាំបាច់ត្រូវមានការគាំទ្រយ៉ាងពេញទំហឹងពី ក.ក.ច.ន.យ ពីព្រោះមានបញ្ហាប្រឈមច្រើនណាស់ ៖

-ការខ្វះខាតថវិកា សម្ភារៈបរិក្ខា

-តុលាការទាំងអស់នឹងត្រូវគោរពច្បាប់ដែលនឹងត្រូវអនុម័តជាបន្តបន្ទាប់ ប៉ុន្តែសម្រាប់តុលាការយើង

សព្វថ្ងៃមានការលំបាក ក្នុងការអនុវត្តណាស់

-ច្បាប់ចាំបាច់ខ្លះមិនទាន់បានអនុម័តនៅឡើយទេ

-ឯកសារដែលដាក់ជូនអង្គប្រជុំនេះ គឺជាឯកសារមួយដែលត្រូវការពិភាក្សាលើក្រមនីតិវិធីព្រហ្មទណ្ឌ

ទាំងមូល

-តើថវិកាសម្រាប់ការចុះស៊ើបអង្កេតនៅឯណា ?

-ចំនួនព្រះរាជអាជ្ញានៅតាមតុលាការគ្រប់គ្រាន់ឬទេ ?

-តើព្រះរាជអាជ្ញាមានសមត្ថភាព និងអំណាចគ្រប់គ្រងនគរបាលយុត្តិធម៌ឬទេ ?

លោក Ian McPhee ទីប្រឹក្សា CCJAP សម្រាប់ក្រសួងយុត្តិធម៌ និងតុលាការបានសួរបញ្ជាក់ថា ដំណើរការ នេះ ត្រូវបានសម្រេចនៅកិច្ចប្រជុំលើកមុនរួចហើយ ឬមួយយើងត្រូវសំរេចនៅថ្ងៃនេះ ?

លោក Trier បានមានប្រសាសន៍ថា លោកសូមជូនជាព័ត៌មានថា នៅ Green Land យើងមានបញ្ហាដូចគ្នា នឹងកម្ពុជាដែរ ពាក់ពន្ធ័ដល់បញ្ហាក្របខណ្ឌ័ច្បាប់ និងទីតាំងតុលាការ ប៉ុន្តែយើងពុំឃើញមានការប៉ះពាល់ដល់កំណែទម្រង់ តុលាការ ដែលយើងកំពុងធ្វើទេ ។តុលាការនីមួយៗត្រូវតែរៀបចំខ្លួនដើម្បីឆ្លើយតបទៅនឹងច្បាប់ថ្មីជាដរាប ។ ឆ្លើយតប ទៅនឹងសំណួរថា តើត្រូវជ្រើសរើសតុលាការគំរូបែបណានោះ លោកមានប្រសាសន៍ថា នេះជាសមត្ថកិច្ចរបស់ក្រុមការងារបច្ចេកទេស ។ សម្រាប់យោបល់លោកផ្ទាល់ គួរតែជ្រើសរើសយកតុលាការណាដែលមានរឿងក្តីច្រើន ពីព្រោះ យើងត្រូវការស្ថិតដើម្បីវាស់វែងសន្ទុះនៃការបំពេញមុខងារ ។ លោកបានបញ្ជាក់ទៀតថា តុលាការគំរូមានសារៈសំខាន់ ណាស់ សម្រាប់កំណែទម្រង់ លោកពុំមើលឃើញថា ការបង្កើតតុលាការគំរូនាំឱ្យរំខានដល់កំណែទម្រង់ទេ ។

លោក Thomas Trier បានមានប្រសាសន៍បន្ថែមទៀតថា យើងត្រូវបង្កើតក្រុមការងារបច្ចេកទេសមួយ សម្រាប់រៀបចំការងារតុលាការគំរូដែលមានការចូលរួមពីមន្ត្រីស្ថាប័នពាក់ពន្ធ័ ដូចជាក្រសួងយុត្តិធម៌ តុលាការ និងឧត្តម ក្រុមប្រឹក្សានៃអង្គចៅក្រម ។ ទាក់ទិននឹងការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ លោកបានយល់ស្របជាមួយនឹងវាគ្មិនខាងលើថា មានការលំបាក ហើយចំពោះការអនុវត្តគម្រោងបង្កើតតុលាការគំរូនេះទាញទាមទារនូវ ចំណេះដឹងរបស់មន្ត្រីតុលាការ ។

ដូច្នេះយើងត្រូវតែផ្តល់នូវវគ្គបណ្តុះបណ្តាលបន្ថែមទៀត នៅតាមកំរិតចេះដឹងដែលពួក គាត់មានស្រាប់ ។ ដូច្នេះ DIHR នឹងរៀបចំឱ្យមានការបណ្តុះបណ្តាលមន្ត្រីដែលត្រូវបានជ្រើសរើសជាសមាជិក នៃក្រុមការងារបច្ចេកទេសនេះ ។

ឯកឧត្តម **ជីវ កេង** ប្រធានតុលាការក្រុងភ្នំពេញ បានមានប្រសាសន៍រំលឹកជូនអង្គប្រជុំថា គម្រោងបង្កើត តុលាការគំរូនេះគឺ ជាផែនការសកម្មភាពរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលបានអនុម័តដោយ ទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ កន្លងទៅនេះ ។ ដូច្នេះយើងត្រូវតែរួបរួមគ្នាអនុវត្តឱ្យបាន

សំរេច ។ តុលាការគំរូជាតុលាការ ដែលតុលាការផ្សេងទៀតធ្វើតាមនៅពេលអនាគត ។ បញ្ហាដែលយើងត្រូវដោះស្រាយគឺ ដំបូងត្រូវជ្រើសរើសតុលាការគំរូ ហើយយើងត្រូវធ្វើឱ្យបានគ្រប់រឿងក្តី មិនមែនតែរឿងក្តីព្រហ្មទណ្ឌ ប៉ុណ្ណោះទេ ។

រឿងបង្កើតតុលាការគំរូនេះ គឺដើម្បីជួយដោះស្រាយជូនប្រជាពលរដ្ឋ ។ បើតាមគំនិតរបស់ឯកឧត្តម ដើម្បី កំណត់ស្តង់ដារ និងលក្ខណៈវនិច្ឆយ័សម្រាប់តុលាការគំរូ យើងគួរគិតគូដល់ធាតុប្រាំយ៉ាងដូចខាងក្រោម ៖

1- ការគោរពច្បាប់ និងនីតិវិធីនៃការងារ

2- សេវាកម្មល្អ(ផ្តល់សេវាកម្មល្អ ងាយស្រួលដល់ការទំនាក់ទំនង)

3- ត្រូវមានមន្ត្រីល្អដូចជា ចៅក្រមល្អ មេធាវីល្អ ព្រះរាជអាជ្ញាល្អ ជាដើម

4- សហការល្អ ទំនាក់ទំនងល្អ(ទំនាក់ទំនងល្អជាមួយមន្ត្រីពាក់ពន្ធ័)

5- សមត្ថភាពគ្រប់គ្រងល្អ ។

លក្ខណៈវនិច្ឆ័យនេះមានភ្ជាប់ជាមួយរបាយការណ៍នេះ ។

ឯកឧត្តម ទី ឈោង អនុប្រធានសាលាឧទ្ធរណ៍ យល់ស្របនឹងមតរបស់ឯកឧត្តម ជីវ កេង តែសុំបន្ថែមថា

លើសពីចំណុចទាំងប្រាំនោះ យើងត្រូវមានចំណុចពីរទៀត គឺទីតាំង និងសម្ភារៈគ្រប់គ្រាន់។

លោកស្រី Anna អ្នកតំណាងអង្គការ UNICEF បានមានប្រសាសន៍ថា UNICEF រីករាយនឹងគាំទ្រដំណើរការ
រៀបចំគម្រោងបង្កើតតុលាការគំរូនេះ ហើយលោកស្រីបានបញ្ជាក់ថា នេះជាលើកទីមួយដែលលោកស្រីបានចូលរួម ប្រជុំពាក់ពន្ធ័នឹងដំណើរការកំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ ។ លោកស្រីបានជូនព័ត៌មានថា បច្ចុប្បន្ននេះ UNICEF បានជ្រើសរើសខេត្ត-ក្រុង ចំនួន ៤ គឺ ភ្នំពេញ ខេត្តកណ្តាល ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ សម្រាប់ការ សាកល្បងការអនុវត្តយុត្តិធម៌អនីតិជន ។ លោកស្រីបានចោទសួរថាតើ UNICEF ត្រូវបញ្ចូលគម្រោងរបស់ខ្លួនក្នុងកម្មវិធីសកម្មភាពរបស់កំណែទម្រង់ច្បាប់ និងតុលាការឬយ៉ាងណា?

ឯកឧត្តម ស៊ុំ ម៉ានិត បានស្វាគមន៍ចំពោះគាំទ្រ UNICEF ក្នុងកំណែទម្រង់ ហើយឯកឧត្តមបានមានប្រសាសន៍ ថា សកម្មភាពណាដែលពាក់ព័ន្ធនឹងកំណែទម្រង់គួរតែបញ្ចូលក្នុងបញ្ជីសកម្មភាពនៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និង តុលាការ ។

លោក Bent Vase ទីប្រឹក្សាយុទ្ធសាស្ត្រមកពី DIHRបានមានប្រសាសន៍ថា ដំណើរការនៃការបង្កើតតុលាការ គំរូ ដែលយើងលើកយកមកពិភាក្សាថ្ងៃនេះ គឺអនុលោមទៅតាមស្មារតីនៃការប្រជុំកាលពីថ្ងៃទី **២៦** ខែ សីហា ឆ្នាំ **២០០៦** កន្លងមក ។ ដំណើរការនេះពាក់ពន្ធ័នឹងចំណុចទាំងប្រាំដូចខាងក្រោម ៖

- ត្រូវពិភាក្សាថា តើអ្វីខ្លះដែលត្រូវធ្វើឱ្យបានត្រឹមត្រូវនោះ ?
- បន្ទាប់មកយើងនឹងរកវិធីសាស្ត្រ និងវិធានការដែលត្រឹមត្រូវ
- យើងត្រូវទទួលស្គាល់ថា អ្នកដែលបានចូលរួមនៅទីនេះ គឺជាក្រុមការងារជាន់ខ្ពស់
- ដើម្បីបំពេញចំណុចសំខាន់ទាំងអស់នេះ យើងត្រូវពិភាក្សាលំអិតថែមទៀត
- បន្ទាប់មកយើងធ្វើការតាមដាន និងអនុវត្តន៍ ។

ឯកឧត្តម **ស៊ុយ** **ម៉ុងលាង** បានធ្វើការកត់សំគាល់ថា ការប្តូរយោបល់គ្នានៅថ្ងៃនេះមានការយល់ស្របគ្នាច្រើន
ឯកឧត្តមបានធ្វើការបកស្រាយបំភ្លឺបន្ថែមនូវអ្វីដែលលោក Trier បានបង្ហាញជូនស្តីពីការរៀបចំតុលាការគំរូ និងថា តើយើងត្រូវធ្វើកិច្ចការអ្វីបន្ត ? បន្ទាប់ពីខែ សីហា ឆ្នាំ **២០០៦** យើងបានសម្រេចថា យើងនឹងធ្វើការងារជាបន្តរួចទៅ ហើយ ។

ការងាររៀបចំស្តង់ដាតុលាការគំរូកម្ពុជាភាគច្រើនពាក់ព័ន្ធនឹងការងារព្រហ្មទណ្ឌ ប៉ុន្តែការងារនេះជាផ្នែកមួយរបស់តុលាការតែ ប៉ុណ្ណោះ ក្រុមការងារបច្ចេកទេសនឹងធ្វើការបន្តទៅលើផ្នែកផ្សេងៗ ទៅតាមភាពជាក់ស្តែង ។ ដូច្នេះ ហើយបានជាលោក Trier ចៅក្រមមកពីដាណឺម៉ាកធ្វើបទបង្ហាញជូនអំពីអ្វីដែលយើងមិនទាន់បានធ្វើ និងថាតើអ្វីទាំងនោះ យើងត្រូវធ្វើយ៉ាងណាជាបន្ត ។ ដូច្នេះយើងនឹងបង្កើតក្រុមការងារដើម្បីធ្វើការងារបន្ត ។ នៅពេលដែលក្រុមការងារ បច្ចេកទេសបង្កើតឡើង យើងនឹងកំនត់លក្ខខណ្ឌ វនិច្ឆ័យសម្រាប់តុលាការគំរូ ។

ឯកឧត្តម **ឌី ឈាង** បានគាំទ្រគំនិតនេះនឹងគំនិតរបស់ UNICEF ខាងលើផងដែរ ។

ឯកឧត្តម **ស៊ុយ ម៉ុងលាង** មានប្រសាសន៍ថា ក្រុមការងារជាន់ខ្ពស់ គឺមាន ឯកឧត្តម លោកជំទាវ ជាថ្នាក់ ដឹកនាំដែលបានអញ្ជើញមកចូលរួមប្រជុំនាថ្ងៃនេះ រួមទាំងតំណាងអង្គការអ្នកផ្តល់ជំនួយផងដែរ ។ ក្រុមនេះនឹងពិនិត្យមើល បញ្ហាទាក់ទងនឹងគោលនយោបាយ ហើយការងារបច្ចេកទេស គឺជាភារកិច្ចរបស់ក្រុមការងារបច្ចេកទេសកម្ពុជា ។ សមាសភាព ក្រុមការងារបច្ចេកទេសមានតំណាងក្រសួងយុត្តិធម៌ តំណាងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ តំណាងតុលាការ ខេត្តកណ្តាល តំណាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តំណាងតុលាការកំពូល តំណាងសាលាឧទ្ធរណ៍ តំណាងតុលាការភ្នំពេញ និងមន្ត្រីដែលពាក់ព័ន្ធតាមការចាំបាច់ ។ ឯកឧត្តមបន្តទៀតថា ក្រុមការងារបច្ចេកទេសនេះ នឹងធ្វើផែនការសកម្មភាព សម្រាប់គម្រោងតុលាការគំរូ ។

ឯកឧត្តម **ស៊ុំ ម៉ានិត** បានសំណូមពរដល់ឯកឧត្តម-លោកជំទាវដែលបានចូលរួមអង្គប្រជុំធ្វើជាសមាជិកនៃ ក្រុមការងារជាន់ខ្ពស់សម្រាប់គម្រោងបង្កើតតុលាការគំរូនៅកម្ពុជា ។

ឯកឧត្តម **ហង់ រ៉ូវ៉ាកេន** បានប្រកែកថា លោកមិនអាចចូលបានទេ ព្រោះលោករវល់ណាស់ ហើយនៅសាលា ឧទ្ធរណ៍មានព្រះរាជអាជ្ញាតែពីរនាក់ប៉ុណ្ណោះ ។

ឯកឧត្តម **ឌី ឈាង** បានមានប្រសាសន៍ថា ឯកឧត្តម **ហង់ រ៉ូវ៉ាកេន** ត្រូវតែចូលរួមជាសមាជិក ព្រោះ លោកទទួលបន្ទុករឿងក្តីព្រហ្មទណ្ឌ ។

ឯកឧត្តម **ស៊ុំ ម៉ានិត** បានយល់ស្របតាមមតិឯកឧត្តម ឌី ឈាង ហើយមានប្រសាសន៍ថា ឯកឧត្តម ហង់ រ៉ូវ៉ាកេន ត្រូវតែជួយយើងខ្ញុំ ហើយសុំឱ្យឯកឧត្តម ស៊ុយ ម៉ុងលាង រៀបចំសេចក្តីសម្រេចដាក់ជូនសហប្រធានក្រុម ប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ។

ឯកឧត្តម **ហង់ វុរ៉ាកេន** សម្របសម្រួលតាមមតឯកឧត្តម **ស៊ុំ ម៉ានិត** តែនៅមានចម្ងល់អំពីក្រុមការងារបច្ចេកទេស។

ឯកឧត្តម **ស៊ុយ ម៉ុងឈាង** បានបំភ្លឺបន្ថែមថា ក្រុមការងារមានពីរ ។ ក្រុមការងារបច្ចេកទេសថ្នាក់ជាតមួយ និងក្រុមមួយទៀតសម្រាប់ធ្វើផែនការការងារ ( Bussiness Plan ) នៅតាមតុលាការគំរូនីមួយៗ ។ ជាមួយគ្នានេះដែរ ឯកឧត្តមបានស្នើដល់អង្គប្រជុំជួយរកលក្ខណៈវនិច្ឆ័យសម្រាប់ជ្រើសរើសតុលាការខេត្ត-ក្រុងដែលត្រូវយកមកធ្វើជាគំរូ ។

លោក Michael Engquist បានមានប្រសាសន៍ថា ក្នុងការជ្រើសរើសតុលាការគំរូគួរតែជ្រើសរើសតុលាការណាដែលមានរឿងក្តីច្រើន ហើយផ្តោតនៅលើលក្ខណៈនៃទីតាំងឧទាហរណ៍ដូចជាតុលាការខេត្តកំពង់ចាមមានពាក់ព័ន្ធនឹង រឿងក្តីពាណិជ្ជកម្ម ដូចជាតុលាការខេត្តបន្ទាយមានជ័យ និងខេត្តរតនៈគីរីមានពាក់ពន្ធ័នឹងរឿងដីធ្លី ជាចុងក្រោយលោកបានលើកឡើងថា តុលាការគំរូគួរមានត្រឹមបីឬបួនសិន ។

លោក Ian McPhee តំណាង CCJAP បានមានប្រសាសន៍ថា តុលាការគំរូមិនមែនផិតនៅតែលើសម្ភារៈ ប៉ុណ្ណោះទេ អ្វីដែលសំខាន់នោះគឺ នីតិវិធីដែលតុលាការនីមួយៗត្រូវយកទៅប្រើឱ្យបានត្រឹមត្រូវ និងមានតម្លាភាព ។

ក្រោយពីឯកឧត្តម **ស៊ុំ ម៉ានិត** បានសុំមតិតំណាងក្រសួង ស្ថាប័ន និងសហគមន៍អ្នកផ្តល់ជំនួយមក អង្គប្រជុំបាន សម្រេចមូលមតិគ្នាជ្រើសរើសតុលាការគំរូចំនួនបួន គឺតុលាការក្រុងភ្នំពេញ តុលាការខេត្តកណ្តាល តុលាការខេត្តកំពង់ចាម និងតុលាការខេត្តបន្ទាយមានជ័យ និងសម្រេចរៀបចំបង្កើតក្រុមការងារជាន់ខ្ពស់ និងក្រុមការងារបច្ចេកទេស ដើម្បីអនុវត្ត ការពង្រីកគម្រោងបង្កើតតុលាការគំរូ ។ អង្គភាពគ្រប់គ្រងគម្រោងជាអ្នកទទួលភារកិច្ចធ្វើការងារឱ្យបានសម្រេចតាមស្មារតី នៃអង្គប្រជុំ ។

អង្គប្រជុំពិភាក្សាបានបញ្ចប់នៅវេលាម៉ោងដប់ប្រាំបី ល្ងាចនាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ*

*ឧសភា ឆ្នាំ ២០០៧*

បានឃើញ និងឯកភាព

ប្រធានអង្គប្រជុំ　　　　　　　　　　　　　　　　　　អ្នកកត់ត្រា

ស៊ុំ ម៉ានិត　　　　　　　　　　　　　　　　　　សេង វ៉ាន់ដា　　　　ស៊ុន សិរីវុធ

## បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា

## នាថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៧

១-ឯកឧត្តម ស៊ុំ ម៉ានិត ប្រធានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍

២-ឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោង

៣-ឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោង

៤-ឯកឧត្តម ឌី ឈោង អនុប្រធានសាលាឧទ្ធរណ៍

៥-ឯកឧត្តម ហង ់រ៉ូ៉ាកេន អគ្គព្រះរាជអាជ្ញា

៦-ឯកឧត្តម ជីវ កេង ប្រធានតុលាការក្រុង

៧-លោក ខៀវ សាម៉េត ប្រធានតុលាការខេត្តកណ្ដាល

៨-លោក ទូច ថារិទ្ធិ ប្រធាននាយកដ្ឋានរដ្ឋប្បវេណី (តំណាងឯកឧត្តម អ៊ី ដន )

៩-លោក អ៊ុក សាវុធ ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ

១០-លោក ហួត វុទ្ធី ព្រះរាជអាជ្ញាអមតុលាការ

១១-លោក ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោង

១២-លោក បួន សុមុនី ប្រធានក្រុមគម្រោងរដ្ឋបាល និងហិរញ្ញវត្ថុ

១៣-លោក ឆែ លី អនុប្រធានក្រុមគម្រោងកំណែទម្រង់តុលាការ

១៤-លោក ឆុង ហួត ប្រធានក្រុមគម្រោងកំណែទម្រង់ច្បាប់

១៥-លោក គង់ ផល្លះ អនុប្រធានក្រុមគម្រោងកំណែទម្រង់ច្បាប់

១៦-លោក កួយ សៅ អនុប្រធានក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម

១៧-លោក ជឹង ផេងស្រួយ ប្រធានក្រុមគម្រោងបណ្ណសារ និងព័ត៌មានវិទ្យា

១៨-លោកស្រី ស្រី ប៊ុណ្ណារត្ន័ ប្រធានក្រុមគម្រោងបណ្ណសារ និងព័ត៌មានវិទ្យា

១៩-លោកស្រី យិន កក្កដា មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ

២០-លោកស្រី សេខ រ៉ង់ដា មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ

២១-លោកស្រី ឈូក សា៉ុម មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ

២២-លោក ស៊ុន សិរីវុធ មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ

២៣- Mr. Filippi Assistant French Cooperation

២៤- Mr. Ben Schultz, Adviser (CCJAP III)

២៥- Mr. Pierre Espieu, Chef de Project, "Appui à L' Etat de Droit France "

២៦- Mr.Kamiki Atsushi (Legal Advisor) JICA

២៧- Mr.Yan Sokha, Project Officer CCJAP III

២៨- Mr. Michael Engquist (Consultant) Danida

២៩- Mr. Ian McPhee, Court Adviser CCJAP III

៣០- Mr.Bent Vast, Adviser, DIHR

៣១- Mrs.Anna Sunga, Child Pro Specialist UNICEF

៣២- Mr.Eric Andre' Andersen, Analyst DIHR

៣៣- Mr.Guillaume Massin, French Cooperation

៣៤ - Mr.Thomas Trier, Hight Court, DIHR